# បុគ្គលិកអនាម័យ

**អង្គការមិត្តសំឡាញ់** ជាអង្គការក្នុងស្រុកនាំមុខគេក្នុងកម្មិធីការពាកុមារ/យុវវ័យគ្រួសារ និងសហគមន៍របស់គេ ។ បច្ចុប្បន្ន អង្គការមិត្តសំឡាញ់ បាននឹងកំពុងផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំ ផ្តល់ការប្រឹក្សា អាហារ កន្លែងស្នាក់នៅ សេវាសុខាភិបាល និងកម្មវិធីតាមថ្នល់ផ្សេងៗគ្នាដល់កុមារ/យុវវ័យ ងាយរងគ្រោះ និងបាត់បង់ឱកាសចំនួន ១៨០០ ក្នុងក្រុងភ្នំពេញ។

មិត្តសំឡាញ់ត្រូវការជ្រើសរើសបុគ្គលិកអនាម័យចំនួន០១នាក់ ធ្វើការប្រចាំនៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។

តួនាទី នឹងការទទួលខុសត្រូវៈ

- រក្សាអនាម័យ និងសោភ័ណ្ឌភាពនៅក្នុងការិយាល័យ និងបន្ទប់ទឹក
- ទទួលខុសត្រូវក្នុងការរៀបចំទីកន្លែង អាហារសម្រន់ និងសម្ភារៈប្រើប្រាស់សម្រាប់ការប្រជុំ ផ្សេងៗ
- ថៃរក្សាគ្រឿងសង្ហារឹម និងសម្ភារៈការិយាល័យឲ្យបានស្អាត និងប្រកបដោយអនាម័យ
- ផ្គត់ផ្គង់សម្ភារៈបន្ទប់ទឹក និងភេសជ្ជៈសម្រាប់បុគ្គលិកជារៀងរាល់ខែ
- ជួយរៀបចំសំអាត និងទុកដាក់សម្ភារៈក្នុងឃ្លាំង
- ជួយការងាររដ្ឋបាលបន្ទាប់បន្សំដូចជា ថតម្លងឯកសារ រៀបចំឯកសារ ។ល។

ល័ក្ខខ័ណ្ឌជ្រើសរើសៈ

- ចេះអាន និងសរសេរភាសារខ្មែរស្ទាត់ជំនាញ
- មានចំណេះដឹងផ្នែកអនាម័យ
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ឡើងពាក់ព័ន្ធការងារផ្នែកអនាម័យ
- មានសុខភាពល្អ និងកាយសម្បទាមាំមួន
- មានភាពស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងចេះបទបែន
- មានភាពអត់ធ្មត់ និងទទួលខុសត្រូវចំពោះការងារ

ទីតាំងការងារៈ ភ្នំពេញ
ថិរវេលាៈ ការងារពេញម៉ោង

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាស័យដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦/ ០១៦ ៩២៣ ១៥៩/ ០១២ ៩៧៦ ៨៨៩

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍ ។ ស្ត្រីត្រូវបានលើកទឹកចិត្ត ។

អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៍ការពារកុមារ។
ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។